NEWS RELEASE

UNITED NATIONS
HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER
South-East Asia Regional Office

## ទិវាអន្តរជាតិនៃជនរងគ្រោះពីការបាត់ខ្លួនដោយបង្ខំ ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២០

## ការិយាល័យសិទ្ធិមនុស្សអង្គការសហប្រជាជាតិប្រចាំតំបន់អាស៊ីអាគ្នេយ៍

ទីក្រុងបាងកក (៣០ សីហា ២០២០) – ដោយមានការសម្តែងនូវកង្វល់យ៉ាងខ្លាំងអំពីរបាយការណ៍ស្តីពីការបាត់ខ្លួនដោយបង្ខំដែលបានបន្តកើតមាននៅក្នុងប្រទេសមួយចំនួននៅអាស៊ីអាគ្នេយ៍ ការិយាល័យសិទ្ធិមនុស្ស អ.ស.ប កំពុងអំពាវនាវជាបន្ទាន់ដល់បណ្តារដ្ឋទាំងឡាយក្នុងតំបន់ឲ្យចាត់វិធានការចំពោះឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរនេះ និងចាត់ជាអាទិភាពនូវការផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិដើម្បីការពារមនុស្សទាំងអស់ពីការបាត់ខ្លួនដោយបង្ខំ។

"ពេលវេលាបានបញ្ចប់ឧក្រិដ្ឋកម្មដ៏សាហាវទាំងនេះនៅអាស៊ីអាគ្នេយ៍។ ត្រូវមានការប្តេជ្ញាចិត្តដ៏រឹងមាំពីរដ្ឋទាំងឡាយដើម្បីសម្រេចគោលដៅនោះ តាមរយៈ ការអនុម័តច្បាប់ក្នុងប្រទេសដែលស្របតាមនិយាម និងបទដ្ឋានអន្តរជាតិ និងដោយត្រូវអនុវត្តយ៉ាងពេញលេញនូវអនុសញ្ញានោះ រាប់ទាំងការបង្កើតយន្តការស្ថាប័នក្នុងប្រទេសដែលមានលក្ខណៈសមស្រប ដើម្បីធ្វើការស៊ើបអង្កេតលើការចោទប្រកាន់អំពីការបាត់ខ្លួនទាំងឡាយ" លោកស្រី Cynthia Veliko តំណាងប្រចាំតំបន់នៃការិយាល័យសិទ្ធិមនុស្សនៅទីក្រុងបាងកក បានមានប្រសាសន៍ដូច្នេះនៅក្នុងសេចក្តីថ្លែងការណ៍មួយពេលដែលប្រារព្ធទិវាអន្តរជាតិនៃជនរងគ្រោះពីការបាត់ខ្លួនដោយបង្ខំ។

មានតែប្រទេសមួយទេនៅអាស៊ីអាគ្នេយ៍ គឺប្រទេសកម្ពុជា ដែលបានផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិមួយនេះ ហើយប្រទេសចំនួនបីផ្សេងទៀតគឺ ប្រទេសឥណ្ឌូណេស៊ី ប្រទេសឡាវ និងប្រទេសថៃ គឺជាប្រទេសហត្ថលេខី ប៉ុន្តែមិនទាន់ក្លាយជារដ្ឋភាគីនៅឡើយទេ។

ក្រុមការងារអ.ស.ប ស្តីពីការបាត់ខ្លួនដោយបង្ខំ ឬដោយមិនមានការស្ម័គ្រចិត្ត ដែលមានអាណត្តិត្រូវជួយដល់ក្រុមគ្រួសារទាំងឡាយក្នុងការកំណត់ជោគវាសនា ឬកន្លែងស្នាក់នៅរបស់ជនរងគ្រោះ បានចងក្រងឯកសារយ៉ាងហោចណាស់ដល់ទៅ ១ករណី ៣០១. ដែលនៅតែមិនទាន់បានដោះស្រាយនៅអាស៊ីអាគ្នេយ៍នៅឡើយ។ ស្ទើរតែពាក់កណ្តាលនៃករណីទាំងនោះគឺកើតមាននៅប្រទេសហ្វីលីពីន។ ក្នុងរយៈពេលបីឆ្នាំកន្លងមកនេះ ករណីនៃ

ការបាត់ខ្លួនដោយបង្ខំត្រូវបានគេរាយការណ៍ថាកើតមាននៅក្នុងប្រទេសកម្ពុជា ប្រទេសឡាវ ប្រទេសម៉ាឡេស៊ី ប្រទេសហ្វីលីពីន ប្រទេសថៃ និងប្រទេសវៀតណាម។ ប្រទេសម៉ាឡេស៊ីកំពុងតែដោះស្រាយគេរតំណែលជាប្រវត្តិសាស្ត្រនៃការបាត់ខ្លួនដោយបង្ខំ រាប់ទាំងការបាត់ខ្លួនទាំងឡាយដែលបានកើតមាននៅប្រទេសទីម័រខាងកើត។

លោកស្រី Veliko បានមានប្រសាសន៍ថា ការបាត់ខ្លួនដោយបង្ខំ"អាចជាការរំលោភសិទ្ធិមនុស្សមួយអាក្រក់បំផុត ដោយអាចរាប់ថាជាការប្លន់ក្រុមគ្រួសារទាំងឡាយនូវចំណេះដឹង ជោគវាសនារបស់មនុស្សជាទីស្រលាញ់របស់ពួកគេ ជារៀងរហូត ។"គ្រួសារទាំងនោះមានសិទ្ធិដឹង ហើយវាជាទំនួលខុសត្រូវរបស់រដ្ឋាភិបាលទាំងឡាយ ក្នុងការដោះស្រាយជាបន្ទាន់នូវករណីទាំងនេះ ដាក់ចេញនូវយន្តការនានាដើម្បីបង្ការកុំអោយវាកើតមានឡើង ហើយបំពេញកាតព្វកិច្ចរបស់ខ្លួនក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិផង"។

អនុសញ្ញាបានកំណត់ពីការបាត់ខ្លួនដោយបង្ខំថាជា 'ការចាប់ខ្លួន ការឃុំខ្លួន ការចាប់ពង្រត់ ឬទម្រង់ណាមួយផ្សេងទៀតនៃការដកហូតសេរីភាព ដោយភ្នាក់ងាររដ្ឋ ឬដោយបុគ្គល ឬក្រុមមនុស្សដែលធ្វើសកម្មភាពដោយមានការអនុញ្ញាត ការគាំទ្រ ឬការទទួលយល់ព្រមឲ្យធ្វើពីរដ្ឋ ដោយក្រោយមកមានការបដិសេធមិនទទួលស្គាល់ការដកហូតសិទ្ធិសេរីភាព ឬដោយមានការលាក់បាំងនូវជោគវាសនា ឬកន្លែងលាក់ខ្លួនរបស់មនុស្សដែលបាត់ខ្លួន ដែលដាក់មនុស្សបែបនេះនៅខាងក្រៅពីការការពារដោយច្បាប់។ អនុសញ្ញានេះចែងថា គ្មាននរណាម្នាក់ត្រូវទទួលរងនូវសកម្មភាពបែបនេះដោយមិនមានការលើកលែង សូម្បីតែក្នុងពេលមានសង្គ្រាមក៏ដោយ ហើយក៏ចែងផងដែរថា សកម្មភាពបែបនោះបង្កើតជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅពេលដែលអនុវត្តក្នុងលក្ខណៈរីករាលដាល ឬជាប្រព័ន្ធ។

នៅអាស៊ីអាគ្នេយ៍ បុគ្គលជាច្រើនត្រូវបានគេកំណត់គោលដៅសម្រាប់ការអនុវត្តសិទ្ធិជាមូលដ្ឋានរបស់ពួកគេនូវសេរីភាពខាងការបញ្ចេញមតិ ការបង្កើតសមាគម និងការជួបជុំដោយសន្តិវិធី។ ជនរងគ្រោះទាំងនោះ រួមមាន អ្នកការពារសិទ្ធិមនុស្ស សកម្មជនបរិស្ថាន និងសកម្មជននយោបាយ អ្នករិះគន់រដ្ឋាភិបាល មេធាវី និងអ្នកសារព័ត៌មាន។

លោកស្រី Veliko បានមានប្រសាសន៍ថា "និទណ្ឌភាពចំពោះអំពើដ៏គួរឱ្យរន្ធត់នេះត្រូវតែបញ្ចប់។ ការស៊ើបអង្កេតទាន់ពេលវេលា និងគួរឱ្យទុកចិត្តត្រូវតែធ្វើឡើង ជនល្មើសត្រូវតែកំណត់អត្តសញ្ញាណ និងនាំយកមកទៅកាត់ទោស ហើយក្រុមគ្រួសារជនរងគ្រោះត្រូវទទួលបាននូវសិទ្ធិទទួលសំណង"។ លោកស្រីក៏មានប្រសាសន៍ផងដែរថា "មិនគួរមានការពន្យារពេលបន្ថែមទៀតក្នុងការធ្វើឱ្យមានការផ្តន្ទាទោសនៅក្នុងប្រទេសណាមួយឡើយ ព្រមទាំងត្រូវមានបទដ្ឋានច្បាប់ដែលធានានូវការបង្ហាញយ៉ាងពេញលេញនូវតម្លាភាព និងគណនេយ្យភាពសម្រាប់មនុស្សទាំងអស់ដែលត្រូវបានគេដកហូតសិទ្ធិសេរីភាព"។

ការិយាល័យសិទ្ធិមនុស្សអង្គការសហប្រជាជាតិប្រចាំនៅទីក្រុងបាងកក ប្ដេជ្ញាធ្វើការជាមួយរដ្ឋទាំងឡាយដើម្បីធានាឲ្យសម្រេចបាននូវគោលដៅទាំងនោះ។

ចប់

*ការិយាល័យប្រចាំតំបន់អាស៊ីអាគ្នេយ៍នៅទីក្រុងបាងកក តំណាងឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស ប្រចាំតំបន់អាស៊ីអាគ្នេយ៍។ ឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស គឺជាមន្ត្រីសិទ្ធិមនុស្សដ៏សំខាន់របស់អង្គការសហប្រជាជាតិ និងជាប្រធានការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ដែលដឹកនាំកិច្ចខិតខំប្រឹងប្រែងផ្នែកសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ។*

***សម្រាប់ព័ត៌មានបន្ថែម និងសាកសួរអំពីប្រព័ន្ធផ្សព្វផ្សាយ សូមទាក់ទង៖*** នៅទីក្រុងបាងកក លោក Todd Pitman តាមរយៈលេខទូរស័ព្ទ (+៦៦ ៦៣ ២១៦ ៩០៨០ / តាមរយៈអ៊ីមែល៖ todd.pitman@un.org) ឬ លោកស្រី Wannaporn Samutassadong តាមរយៈទូរស័ព្ទលេខ (+៦៦ ៦៥ ៩៨៦ ០៨១០ / តាមរយៈអ៊ីមែល៖ wannaporn.samutassadong@un.org)។

សូមថេក និងចែករំលែក តាមរយៈធ្វីតធឺរ៖ ***@OHCHRAsia*** និងតាមរយៈហ្វេសប៊ុក៖ ***OHCHRAsia***